# ស្វែងយល់ពីពិធីបំបួសនាគ

*ដោយ* : **លោកស្រីបណ្ឌិត ជា វណ្ណី**
*ប្រធាននាយកដ្ឋានធម្មសាស្ត្រ ចរិយាសាស្ត្រនិងយេនឌ័រ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*ថ្ងៃសង្គមខ្មែរ គឺជាសង្គមមួយដែលគោរពជឿលើព្រះពុទ្ធសាសនា។ តាមជំនឿក្នុងព្រះពុទ្ធសាសនានៃសង្គមខ្មែរ គេយល់និងឱ្យតម្លៃជាខ្លាំងទៅលើការ"បួស" ឬ "បំបួស ថាបានអានិសង្សនិងជាស្រែបុណ្យដ៏ប្រសើរតទៅជាតិមុខ ហើយអ្វីដែលពិសេសជាងនេះ នៅក្នុងបរិបទនៃវប្បធម៌ប្រពៃណីទំនៀមទម្លាប់ខ្មែរ គេចាត់ទុកការបួសនេះជាផ្នែកមួយនៃទំនៀមក្នុងដំណើរឆ្លងវ័យរបស់មនុស្សប្រុស។ ក្មេងប្រុសកាលបើវិវត្តន៍ចូលវ័យជំទង់ហើយ ជាទូទៅ(កាលពីសម័យបុរាណ) គឺតែងតែទៅបួស រីឯក្មេងស្រីកាលបើវិវត្តន៍ទៅពេញរូបពេញរាង ឬពេញក្រមុំ (គ្រប់ការ)គឺតែងតែចូលម្លប់ ដ្បិតកាលពីជំនាន់នោះមិនទាន់មានសាលារៀនតាមបែបអាណាចក្រឱ្យសប្បុរបែបដូចបច្ចុប្បន្ននេះទេ។*

*ការបួសក្នុងសង្គមខ្មែរមានច្រើនបែបច្រើនយ៉ាងណាស់ ដែលមានដូចជា ការបួសមុខភ្លើង ការបួសលាបំណន់ ការបួសសងគុណ ការបួសរៀនតាមផ្លូវពុទ្ធចក្រជាដើម។ ចំពោះបុរសដែលបានឆ្លងកាត់ការបួសរៀនអស់ពេលជាច្រើនវស្សាហើយ លុះចាកសិក្ខាបទ ឬលាចាកផ្នួស(សឹក)មកវិញ បុរាណលោកឱ្យតម្លៃខ្ពស់ណាស់ ដ្បិតលោកយល់ថា អ្នកបានបួសរៀននោះ គឺបានចេះដឹងក្នុងផ្លូវធម៌បានច្រើន មានចរិយាមារយាទល្អ ហើយលោកតែងតែអ្នកធ្លាប់បួសរៀនទា*

នោះថា **អន្ទិត។** ដែលពាក្យនេះនិយាយក្លាយពីពាក្យថា "បណ្ឌិត"[១] ។

នៅក្នុងការបួសរៀនតាមពុទ្ធចក្រ គេតែងតែហៅពាក្យសម្គាល់ការបួសនោះថា បំបួសនាគខ្លាន និងបំបួសនាគ គឺជាពិធីតែមួយដែលហៅសម្គាល់លើការបំបួសកុលបុត្រ។

**ហេតុដូចម្ដេចបានជាការបំបួសកុលបុត្រ ហៅថា ការបំបួសនាគ?**

មុននឹងធ្វើការបកស្រាយពីចម្ងល់នេះ តើងយើយល់ពាក្យ **បំបួស** និងពាក្យ **នាគ** ជាមុនសិន។

. **បំបួស** (កិ.)ធ្វើឱ្យបួស, ធ្វើឱ្យបានជាអ្នកបួស, ញ៉ាំងកុលបុត្រឱ្យបួស : បំបួសកូនជាសាមណេរ។[២]

. **នាគ** អានថា នាក សំ. បា.( គុ. ឬ ន.) ប្រសើរ, ចម្បង, បរិសុទ្ធ។ ព្រះសព្វញ្ញុពុទ្ធ, ព្រះបច្ចេកពុទ្ធ, ព្រះអរហន្តទាំងអស់ហៅថា នាគ ព្រោះលោកលះលែងធ្វើបាបដោយដាច់ខាតហើយ។ អនាគាមិបុគ្គល ក៏ហៅថា នាគ ព្រោះលោកលែងអន្ទោលវិលត្រឡប់មកកើតក្នុងលោកនេះទៀតហើយ។ អរិយបុគ្គលដែលបានសម្រេចស្រោតា[៣] និងសកិទាគា ក៏ហៅថា នាគ ព្រោះលោកខ្លើមខ្លាចរអាចំពោះអំពើអាក្រក់ពិតប្រាកដ

---

[១] ជួន ណាត *វចនានុក្រមខ្មែរ*បណ្ឌិត ប័ន-ឌិត ឬ បន់-ឌិត បា.(ន.) ជនអ្នកមានប្រាជ្ញាឈ្មោះ បណ្ឌា, ជនអ្នកប្រព្រឹត្តល្អគឺអ្នកកាន់សុចរិត១០ប្រការ, ឬដោយពិស្ដារ, កាន់សុចរិត៤០ប្រការដោយខ្ជាប់ខ្ជួនហ្មត់ចត់ជានិច្ច; អ្នកប្រាជ្ញខាងផ្លូវសុចរិតយុត្តិធម៌ (ព. ពុ.)។ ព. ផ្ទ.ពាល។ ពាក្យសាធារណៈថា អ្នកមានចំណេះជ្រៅជ្រះ, អ្នកឈ្លាសវៃ, អ្នកប្រាជ្ញ។ តាមទម្លាប់ខ្មែរក្នុងសម័យបុរាណដែលគេគោរពព្រះពុទ្ធសាសនាណាស់, សូម្បីគ្រហស្ថកំលោះដែលទើបសឹកចាកផ្នួសថ្មីៗ គេក៏ហៅអ្នកនោះថា **បណ្ឌិត** ដែរ, ហៅក្លាយមកថា **បន្ទិត**, ហៅក្លាយឃ្លាតមកថា **អន្ទិត** ព្រោះគេយល់ថា អ្នកនោះបានបួស មានការចេះដឹង មានចរិយាមារយាទត្រឹមត្រូវ...។ ពាក្យសន្មតប្រើតាមសម័យនិយម, ហៅអ្នកមានវិជ្ជាថ្នាក់ខ្ពស់ដែលមានសញ្ញាបត្រ **ដុកតូរ៉ាត់** (Doctorat) ថា **បណ្ឌិត ដុកទ័រ** (Docteur) តាមឈ្មោះនៃវិទ្យាសាស្ត្រនោះៗ ដូចជា វេជ្ជបណ្ឌិត, បណ្ឌិតខាងច្បាប់, បណ្ឌិតខាងវិទ្យាសាស្ត្រ..., បណ្ឌិតខាងអក្សរសាស្ត្រ ជាដើម...។

[2] ជួន ណាត *វចនានុក្រមខ្មែរ*។

[3] ស្រោតា --ដា សំ.; បា. (ន.) (ស្រោតស៑; សោត)ខ្សែទឹក។ ព. ពុ. ឈ្មោះលោកុត្តរធម៌មួយគូ គឺមគ្គផលជាដើមខ្សែ(ម.ព.សោតាផង)។

ហើយ។ បុគ្គលជាបុថុជ្ជនណាមួយ ដែលកើតមានសេចក្តីអៀនខ្មាស ខ្លាចបាបខំប្រឹងប្រព្រឹត្តចៀសចាកទុច្ចរិត ក៏ហៅថា នាគ។ កុលបុត្រដែលមានសេចក្តីធុញទ្រាន់ចំពោះការនៅគ្រប់គ្រងផ្ទះ មានចិត្តជ្រះថ្លាចូលទៅសូមផ្នួសបួសសំណាក់ក្នុងព្រះពុទ្ធសាសនា ក៏ហៅថា **នាគ** ព្រោះអ្នកនោះផ្តងគំនិតបម្រុងនឹងប្រព្រឹត្តព្រហ្មចរិយធម៌សម្រាប់បព្វជិត។ ដំរីដែលមានរូបរាងស័ក្តិសមប្រសើរក៏ហៅថា នាគ។ ពស់ដែលមានអានុភាពចម្បង ក៏ហៅថា នាគ ។ ដើមខ្នឹង, សំណ ក៏ហៅថា នាគ ។ល។[៤]

ដូច្នេះ បើយោងលើការពន្យល់ពាក្យក្នុងវចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** បំបួសនាគ មានន័យថា ជាការបំបួសកុលបុត្រ មិនថាក្មេងឬចាស់ឡើយ ឱ្យតែបុគ្គលនោះមានសទ្ធាចង់ក្លាយជាព្រះសង្ឃ។ ចំពោះការបួស ប្រសិនបើបុគ្គលនោះចង់បួសត្រឹមតែជាសាមណេរ គឺមិនប្រកាន់អាយុឡើយ តែបើចង់បួសជាភិក្ខុទាល់តែមានអាយុ២០ឆ្នាំពេញឡើងទៅទើបអាចបួសបាន។ ឯបុគ្គលដែលគេហៅថា នាគ គឺជាអ្នកដែលត្រូវបួស ហើយត្រូវស្ថិតក្នុងពេលរៀបចំពិធីបំបួសនោះឯង លុះពេលបំបួសរួចរាល់ បុគ្គលនោះនឹងក្លាយជាព្រះសង្ឃលែងជានាគទៀតហើយ។

ទន្ទឹមនឹងការពន្យល់ពាក្យ បំបួសនាគ មានន័យថាជាការបំបួសកុលបុត្រនោះ ទំនៀមនៃការបំបួសនាគនេះ ក៏មានរឿងព្រេងពីបុរាណបានបកស្រាយបង្ហាញពីបុព្វហេតុនៃការហៅ ការបំបួសកុលបុត្រនេះ ជាការបំបួសដែរផងដែរ ដែលរឿងនិទាននោះមានតំណាលថា៖ *នៅពេលដែលព្រះសម្មាសម្ពុទ្ធទ្រង់គង់នៅក្នុងវត្តជេតពន នាគរាជមួយមានមហិទ្ធិឫទ្ធិ មានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ចង់បួសជាភិក្ខុ ក៏កាឡាខ្លួនជាមាណពចូលទៅថ្វាយបង្គំ**ព្រះមហាតិស្សត្ថេរ** ហើយទូលថា "ខ្ញុំព្រះករុណាសូមបួសជាព្រះមហាថេរផង"។ **ព្រះមហាតិស្សត្ថេរ** ក៏បំបួសស្តេចនាគដែលបានកាឡាខ្លួននោះជាភិក្ខុ។ ថ្ងៃមួយនៅពេលដែលភិក្ខុស្តេចនាគនោះសិងពេលថ្ងៃយ៉ាងស្កប់ស្កល់ខ្លួនលោកក៏ក្លាយជានាគឡាយរង្វេលពេន*

[៤] ជួន ណាត *វចនានុក្រមខ្មែរ*។

ពេញបន្ទប់ រឹងស្បង់ចីវរខ្ចាត់ខ្ចាយអស់លើងពីកាយៗ ពេលនោះសាមណេរមួយអង្គផ្ទង់ចង្កាន់រួចចូលទៅនិមន្តភិក្ខុនោះទៅឆាន់ លុះសាមណេរនោះបើកទ្វារ ក៏ស្រាប់តែឃើញពស់ពេនពេញបន្ទប់ សាមណេរភ័យរន្ធត់ ក៏ស្ទុះរត់ស្រែកឆោឡោផ្អើលពេញវត្ត។ លុះដំណឹងនេះជ្រាបដល់ព្រះពុទ្ធ ទើបព្រះអង្គទ្រង់បញ្ញត្តិថា "ចាប់ពីថ្ងៃនេះ ភិក្ខុឯក្រោយកុំបីបំបួសសត្វតិរច្ឆាន ខ្មោច បិសាច រាជកូត យក្សាឡើយ"។ អាស្រ័យដោយព្រះអង្គទ្រង់បញ្ញត្តិដូច្នេះ ទើបភិក្ខុនាគក្រាបទូលព្រះពុទ្ធថា "ខ្ញុំព្រះអង្គមានចិត្តស្មោះចំពោះសាសនាព្រះអង្គ ពិតណាស់ ឥតមានក្លែងបន្លំទេ បើខ្ញុំព្រះអង្គមានភេទជាសត្វមិនអាចបួសក្នុងសំណាក់ព្រះអង្គបាន ដូច្នេះខ្ញុំព្រះអង្គសូមពរឱ្យមានព្រះបញ្ញត្តិថា បើភិក្ខុនឹងបំបួសកុលបុត្រ សូមឱ្យហៅអ្នកសុំផ្នួសនោះថា "នាគ" ដូច្នេះតទៅ ដើម្បីឱ្យគេនឹកឃើញដល់ឈ្មោះខ្ញុំព្រះអង្គ ដែលជាអ្នកស្មោះចំពោះសាសនាព្រះអង្គ ប៉ុន្តែបែរជាពុំមាននិស្ស័យអាចបួសជាភិក្ខុដូចមនុស្សទាំងពួង។ ព្រះពុទ្ធទ្រង់ទើបបញ្ញត្តិពាក្យឱ្យហៅបព្វជ្ជាបេក្ខៈ (គ្រហស្ថសុំបួសជាសាមណេរ) និងឧបសម្បទាបេក្ខៈ (សាមណេរសុំបួសជាភិក្ខុ) ហៅថា "នាគ" តាមសំណូមពរដែលស្ដេចនាគសុំ។ អាស្រ័យហេតុនេះ ទើបមានឈ្មោះហៅថា "នាគ" រហូតមក។

ការបួសជាព្រះសង្ឃនេះមានន័យថា ព្រះសង្ឃរូបនោះ លោកចង់បំពេញបុណ្យកុសលក្នុងព្រះពុទ្ធសាសនា ចង់បម្រើព្រះពុទ្ធសាសនា និងចង់បំពេញភារកិច្ចជាកូនប្រុសសងគុណមាតាបិតាតែម្ដង។ សម្រាប់លក្ខខណ្ឌនៃការបួស គឺបុគ្គលដែលចង់បួសគេកំណត់ថា ទី១-ត្រូវមានកាយសម្បទាសមរម្យនិងគ្រប់គ្រាន់ ទី២-ត្រូវតែមានការអនុញ្ញាតពីមាតាបិតា ទី៣-ត្រូវតែជាអ្នកមិនជាប់បំណុលគេ និងទី៤-មិនមែនជាអ្នកជាប់ទោស។ បើបុគ្គលនោះមានលក្ខណសម្បត្តិគ្រប់គ្រាន់ ហើយមានសទ្ធាចង់បួស បុគ្គលនោះអាចបួសពេលណាក៏បាន ព្រោះពិធីបំបួសនាគអាចធ្វើបានពេញមួយឆ្នាំមិនមានការកំណត់ឡើយ។ ប៉ុន្តែបើបំបួសនៅថ្ងៃ១៤កើត(ថ្ងៃភោរ) ខែអាសាឍ មុនចូលព្រះវស្សា ២ថ្ងៃ គឺល្មមពេលគ្នានឹងព្រះសង្ឃគង់ចាំព្រះវស្សារយៈពេល៣ខែ តាមព័ទ្ធសីមារបស់ព្រះសម្មាសម្ពុទ្ធ ហើយអ្នកបួសថ្មីអាចយក

ពេលនោះគង់ចាំព្រះវស្សានេះ សិក្សាគម្ពីរធម៌ រៀនសូត្រធម្មវិន័យបានតាមការគួរ។

កាលពីអតីតកាល ពិធីនេះគេធ្វើចំនួនពីរថ្ងៃ ឬបីថ្ងៃ តែបច្ចុប្បន្នពិធីនេះគេធ្វើត្រឹមតែមួយថ្ងៃប៉ុណ្ណោះ។ ពិធីបុណ្យនេះគេអាចរៀបចំធ្វើនៅក្នុងវត្តក៏បាន ឬនៅគេហដ្ឋានរបស់បុគ្គលត្រូវបួសក៏បាន។

មុនថ្ងៃបំបួសចំនួន៣ទៅ៤ថ្ងៃ អ្នកដែលត្រូវចេញទៅបួស ត្រូវកាន់ទៀនធូបទៅជម្រាបលាបងប្អូន និងញាតិមិត្តរបស់ខ្លួន ដើម្បីឱ្យគេបានដឹងផងថា ខ្លួននឹងចូលទៅបម្រើព្រះពុទ្ធសាសនាហើយ។ បើបំបួសសាមណេរ ត្រូវមានរៀបចំស្បង់ ចីវរ បាត្រ កន្ទេល ខ្នើយ។ បើបំបួសជាភិក្ខុវិញ ត្រូវមានត្រៃចីវរ កាំបិតកោរ ថ្មសំលៀង បំពង់ម្ជុល បើមានគ្រប់ទាំង៨មុខ ឬហៅថា អដ្ឋបរិក្ខារក៏ប្រសើរ។ ក្រៅអំពីបរិក្ខារទាំងនេះ មានដបទឹកអប់ បាយសីធំមួយ ធ្វើដោយដើមចេកមួយដើម ដែលមានកម្ពស់ត្រឹមចិញ្ចើមមនុស្សឈរ។ បាយសីនោះមាន១៩ថ្នាក់ ដែលជាតំណាងព្រលឹងមនុស្សទាំង១៩ ប៉ុន្តែមានអ្នកខ្លះ ធ្វើសង្ខេបត្រឹមតែ៩ថ្នាក់។ នៅលើកំពូលបាយសីមានកន្ទោងស្លឹកចេកមួយដាក់បាយព្រលឹង១៩ ឬ៩ពំនូតមានសាជីធ្វើដោយស្លឹកចេកគ្របពីលើ ហើយនៅលើកំពូលសាជីមានដោតទៀនផង។ គេយកស្លឹកចេក៣ជាន់មករុំព័ទ្ធបាយសីនោះ១ជាន់ រួចទើបយកសំពត់ហូលរុំ១ជាន់ពីក្រៅទៀត។

នៅថ្ងៃទី១ ឪពុកម្ដាយរួមទាំងសាមីខ្លួនដែលស្ម័គ្រចិត្តបួសនោះ ត្រូវធ្វើដំណើរមកកាន់វត្តអារាម។ លុះដល់ថ្ងៃត្រង់ វេលាម៉ោង១រសៀល ទើបចាប់ផ្ដើមពិធីកោរសក់ រួចទៅងូតទឹកជម្រះកាយ លាបប្រេងម្សៅតាមការគួរ ហើយនៅខណៈនេះសាច់ញាតិតុបតែងខ្លួនឱ្យនាគ អាចលាបម្សៅ លាបក្រេម បាញ់ទឹកអប់ ពាក់គ្រឿងមាសខ្សែកខ្សែដៃ កងជើង ជាដើម ហើយបំពាក់សំពត់ហូល និងពានាកន្សែងស ឬកន្សែងហូលឱ្យបុគ្គលនោះស្អាតបាត ដែលគេហៅថាជានាគ ឬកូននាគ។ នៅម៉ោង៦ល្ងាច គេមានពិធីសូត្រមន្តចម្រើនព្រះបរិត្តដោយឱ្យនាគចូលទៅអង្គុយជិតបាយសីធំ ដើម្បីស្ដាប់ព្រះសង្ឃចម្រើនព្រះបរិត្ត និងមានឪពុកម្ដាយបងប្អូនក៏ដូចជាក្រុមញាតិមិត្តអង្គុយអមផងដែរ។ បន្ទាប់មកគេរៀបធ្វើពិធី ហៅព្រលឹងនាគ ដែលគ្រានោះ នៅនិគមខ្លះ អាចារ្យកាន់

អំពៅខ្មៅ១ដើមដែលគេទុកឱ្យមានសន្លឹកពីរ ឬបីនៅចុង ហើយចងឱ្យមានទំនងដូចចំពុះបក្សី។ អាចារ្យកាន់ដើមបង្វែរចំពុះនោះនៅគ្រប់ទិស បោយហៅព្រលឹងនាគ បន្ទាប់មកគេរៀបធ្វើធ្មេញ ឱ្យនាគទៀត។ តមកទៀតអាចារ្យរៀបចំបញ្ចុកបាយនាគ គឺគេយកបាយព្រលឹងទៅដាក់ក្នុងទឹកដូងហើយបញ្ចុកមាត់នាគទៅ រួចហើយទើបគេយកអំបោះជ្រលក់ទឹកមន្តចងដៃនាគ។ បន្ទាប់មកទៀត ក្រុមញាតិសាច់សាលោហិតនាំគ្នាអង្គុយជារង្វង់ជុំវិញនាគ ហើយរៀបបង្វិលពពិល ដើម្បីចម្រើនសិរីសួស្តី ជ័យមង្គលដល់នាគនោះ។ ជាធម្មតា គេត្រូវបង្វិលពពិល១៩ជុំ ហើយបក់ផ្សែងសំដៅទៅរកនាគផង។ លុះគ្រប់កំណត់ជុំហើយ អាចារ្យក៏



ពន្ទត់ទៀន រួចយកកំញម លាយជាមួយនឹង



ទឹកអប់បន្តិចយកទៅលាបចិញ្ចើម និងថ្ពាសរបស់នាគ។

នៅថ្ងៃទី២ បន្ទាប់ពីស្រស់ស្រូបអាហារពេលព្រឹករួច សាច់ញាតិជិតខាងនិងបងប្អូនដែលរស់នៅក្បែរវត្ត នាំគ្នាហែហមដង្ហែកូននាគចំនួន៣ជុំព្រះវិហារ ដែលគេជឿថាជាការតំណាងឱ្យព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ។ សូមបញ្ជាក់ថា គេរៀបចំក្បួនដង្ហែនាគចេញទៅវត្តនៅពេលព្រឹកដោយមានភ្លេងផៃយ៉ាំ និងភ្លេងពិណពាទ្យកំដរផង ហើយនាគនោះអាចជិះសេះ ឬគោ និងមានអ្នកបាំងឆ័ត្រឱ្យ ព្រមទាំងហែហម ដោយមានអ្នកម្តាយជាអ្នកទូលត្រៃចីវរ និងលោកឪពុកជាអ្នកស្ពាយបាត្រ និងមានអ្នកកាន់បរិក្ខាផ្សេងៗទៀតផងដែរ។ ជាទូទៅគេ

ស្មៀកហូលឱ្យនាគ ដោយមានពានាកន្សែងពណ៌សឆៀងលើស្មាឆ្វេង និងមានខ្សែក្រវាត់ប្រកបដោយក្បាច់រចនាយ៉ាងស្រស់ស្អាត អាចជាពណ៌ប្រាក់ ឬពណ៌មាសយ៉ាងភ្លឺផ្លេកៗ ក្បួនដង្ហែនេះគេត្រូវដង្ហែបទក្សិណាជុំវិញព្រះវិហារបីជុំទើបហែរចូល ដើម្បីសំដែងសេចក្តីត្រេកអរចំពោះកុលបុត្រដែលបានចូលសាងផ្នួសៗ បើប្រសិនជានាគនោះជាវង្សក្សត្រ ឬជាកូននាម៉ឺនជាន់ខ្ពស់ ការហែនាគមានសភាពគគ្រឹកគ្រេងណាស់ ស្ទើរតែប្រហាក់ប្រហែលនឹងការរៀបចំហែស្តេច១ព្រះអង្គអ៊ីចឹងដែរ ព្រោះកាលដែលព្រះបរមសាស្តាយើង ទ្រង់ចេញទៅសាងព្រះផ្នួសព្រះអង្គជារាជបុត្រាក្សត្រគ្រងរាជ្យៗ នាឱ



កាសនោះ គេឃើញមានភ្លេងឆៃយ៉ាំ ចេញដើរមុខក្បួនមនុស្ស ដែលទូលទ្រពានប្រាក់តម្កល់ត្រៃចីវរ ទ្របាត្រ និងគ្រឿងសក្ការបូជាដើរមុខនាគៗ

ក្រោយពីដង្ហែនាគប្រទក្សិណាព្រះវិហារបីជុំរួចស្រេច គេនាំនាគចូលទៅថ្វាយបង្គំព្រះរតនត្រៃក្នុងព្រះវិហារ រួចទើបធ្វើកិច្ចសំខាន់ចុងក្រោយគឺ "បំបួសនាគ" ឬហៅខ្លីថា "ទាក់កនាគ"ៗ កិច្ចនេះ ត្រូវមានព្រះភិក្ខុសង្ឃច្រើនអង្គគង់តាមវិន័យ បញ្ញត្តិ ហើយនាគម្នាក់ៗត្រូវឆ្លើយឆ្លងធម៌បួសតាមកិច្ចនីមួយៗ ជាមួយនឹងព្រះសង្ឃដែលជាឧបជ្ឈាយ៍ដែលទុកជាគ្រូរបស់ខ្លួន(អ្នកខ្លះហៅថាសុំនិស្ស័យ)ៗ គេយល់ថានៅពេលព្រះ ឧបជ្ឈាយ៍យកស្បង់ចីវរទាក់កនាគទាំងអស់នោះហើយ គឺជាពេលដែលនាគទាំងនោះ បោះបង់ភាពជានាគមកចូលក្នុងភាពជាបព្វជិតដោយដោះសំពត់ហូល ស្បៃពានា និងដោះគ្រឿងអលង្ការនានាអស់ពីខ្លួន ហើយមកគ្រងស្បង់ គ្រងចីវរពេញលេញជាអ្នកបួស ដោយពេលនោះព្រះឧបជ្ឈាយ៍ព្រះអង្គធ្វើកិច្ចនមស្ការព្រះរតនត្រៃ ស្នើសុំនិស្ស័យ និងទាក់កនាគឱ្យក្លាយជាបព្វជិតដោយសូត្រធម៌បំបួសកុលបុត្រៗ នាឱកាសនោះដែរ ព្រះឧបជ្ឈាយ៍ ក៏សាកសួរនូវអ្នកបួសទាំងនោះពីព្រះធម៌ ពីវិន័យ ក៏ដូចជា

ភាសាសង្ឃសព្ទមួយចំនួនដើម្បីជាការវាស់ស្ទង់សមត្ថភាពអ្នកបួសទាំងនោះផងដែរ ព្រោះមុនពេលបួស គឺគេឱ្យកូននាគទាំង



នោះរៀនសូត្រធម៌ រៀនពីវិន័យសង្ឃ និងភាសាសង្ឃសព្ទឱ្យបានចេះចាំជាមុនសិន។

ពាក់ព័ន្ធជំនឿនៃការសាងផ្នួសគេដឹងថា កាលសម័យព្រះបាទអសោកជាអគ្គពុទ្ធសាសនូបត្ថម្ភ ព្រះមោគ្គលិបុត្តតិស្សត្ថេរបានថ្វាយធម្មទេសនាថា " ***ន ហិ បព្វជិតោ បរិឃាតី សម ណោ ហោតិ បរំ វិហេឋយន្តោ*** " មានន័យសេចក្ដីថា " ***បុគ្គលដែលនឹងមានឈ្មោះជាញាតិ ជិតក្នុងព្រះពុទ្ធសាសនា លុះបានបួសខ្លួនឯង ឬបំបួសកូន*** "។ ដោយកើតចិត្តជ្រះថ្លា ព្រះអង្គបានដាក់រាជ្យទ្រង់ផ្នួសមួយគ្រា និងបានបំបួសព្រះរាជបុត្រាព្រះនាម "**មហិន្ទ**" ជាភិក្ខុផង។ រីឯក្នុងនិទានរឿង ***សុបិនកុមារ*** ក៏បានរៀបរាប់ផលអានិសង្សរបស់នាងជាម្ដាយ បានរួចចាកនរក ដ្បិតបានបំបួសសុបិនកុមារជាកូនដូចមានសេចក្ដីជាកាព្យថា៖ [ ] *តេជះផលអានិសង្សមាន កូនប្រុសប្រធាន សំណាក់ក្នុងសាសនា។ មានឈូក មាសមួយសោភា ផុសទ្រុបាទា ខាងនោះអណ្ដែតខ្ពស់ឡើង។ យមបាលសោតចាប់បានជើង ចោលនាងក្នុងភ្លើង ទំហំមួយម៉ឺនយោជន៍យល់។ តេជះកូនបួសជាផលផលនោះមកផ្ដល់ កណ្ដាលនៃភ្លើងអវិចី។ មានឈូកមាសមួយរីកខ្វី ផុសឡើងអំពីមហានរកធំនោះ។*

ដូច្នេះការបួសជាព្រះសង្ឃក្នុងព្រះពុទ្ធសាសនានៅក្នុងសង្គមខ្មែរ ហាក់មានចំណែកពីរគឺ ដោយជំនឿថានឹងបានអានិសង្សទាំងអ្នកបួស និងអ្នកបំបួស ព្រមទាំងជាទំនៀមនៃអរិយធម៌ខ្មែរថា ជាដំណាក់កាលមួយយ៉ាងសំខាន់នៃការធ្វេងវ័យតាមកិច្ចពិធី។ ការបួសនេះសោតក៏សង្កេតឃើញប្រតិបត្តិទាំងក្សត្រ នាម៉ឺន និង ប្រជារាស្ត្រសាមញ្ញ តាំងពីបុរាណកាលរហូតដល់មកសព្វថ្ងៃ។

សូមបញ្ជាក់ថា ពិធីបំបួសនាគ ឬទំនៀមនៃការបួសនាគ ក៏អាចមានលំនាំផ្សេងៗពីគ្នាខ្លះ ខុសគ្នាបន្តិចៗខ្លះដែរ។

ទំនៀមខ្លះដែលគេយល់ឃើញថា មិនត្រឹមត្រូវតាមច្បាប់ព្រះពុទ្ធសាសនា គេក៏កាត់ចោល ហើយទំនៀមខ្លះដែលកើតឡើងតាមកាលៈទេសៈ ក៏ត្រូវបញ្ចូលមកវិញ អាស្រ័យទៅលើការនិយមតាមនិគម ពុំមែនជារបៀបតួយ៉ាង ដែលគេត្រូវតែធ្វើតាមជាដាច់ខាតនោះទេ។

តាមពិតពិធីបំបួសនាគមិនមែនជារឿងថ្មីរបស់ប្រជាពលរដ្ឋខ្មែរនោះទេ ពិធីនេះបានកើតមានតាំងតែពីបុរាណរហូតមកដល់បច្ចុប្បន្ន គឺនៅតែជាទំនៀមទម្លាប់របស់ប្រជាពលរដ្ឋខ្មែរ ព្រោះវាជាស្ពាន ជាសីលសម្រាប់ចម្លងមនុស្សទៅកាន់ភាពរុងរឿងនៃជីវិត វៀរចាកអំពើបាបនិងអបាយមុខទាំងពួង ហើយកើតមានតែភាពស្ងប់ស្ងាត់ មិនលោភលន់ មានចំណេះដឹងខ្ពង់ខ្ពស់ ជួយបំភ្លឺភាពត្រឹមត្រូវដល់មនុស្សជំនាន់ក្រោយជាបន្តបន្ទាប់។

ពិធីនេះជាទូទៅ ច្រើនមាននៅតាមតំបន់ជនបទ យូរៗម្តងគេឃើញមានការរៀបចំធ្វើពិធីនេះនៅទីក្រុងភ្នំពេញ ហើយពិធីបំបួសនាគអាចបានធ្វើឱ្យមានការចាប់អារម្មណ៍ខ្លាំង ប្រសិនបើកូនប្រុសនោះជាកូនរបស់ត្រកូលអភិជនដែលបានសម្រេចចិត្តសាងផ្នួសរយៈពេលខ្លី។ គួររំលឹកថា នៅក្នុងពិធីបំបួសនាគ គេត្រូវរៀបចំធ្វើតាមប្រពៃណីបុរាណ ដូចជាពិធីកោរសក់ ពិធីជូនត្រ័យចំពោះលោកអ្នកមានគុណ ពិធីក្រុងពាលី ពិធីបង្វិលពពិល ពិធីធ្វើធ្មេញនាគ ពិធីកួចចំណងដៃនាគ ពិធីលាបប្រេងម្សៅ ពិធីចម្រើនព្រះបរិត្តនាគ ពិធីហែនាគ ៣ជុំព្រះវិហារ ពិធីចូលព្រះវិហារ ពិធីនាគវន្ទាចំពោះព្រះពុទ្ធរូប ពិធីនាគវន្ទាព្រះឧបជ្ឈាយ៍ ពិធីសុំនិស្ស័យបំបួសនាគ ព្រះឧបជ្ឈាយ៍ ព្រះសង្ឃហត្ថាបាស ចម្រើនពុទ្ធជ័យមង្គល ពិធីពហុទេវា សាមណេរវន្ទាលាញោមប្រុស-ស្រី លោកតា លោកយាយ ដើម្បីសាងផ្នួស និងពិធីកប់សក់ដើម្បីសុំសេចក្តីសុខ។

សរុបមកពិធីបំបួសនាគនេះជាពិធីមួយធំដែលប្រជាជនខ្មែរទម្លាប់ធ្វើតាំងពីបុរាណកាលដែលចូលជ្រួតជ្រាបក្នុងសន្តានចិត្តនៃប្រជាជនខ្មែរ ព្រោះនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញមានចែងថា **ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ**។ រីឯការបំបួសកូនចៅក៏ជាកិច្ចទំនុកបំរុង ព្រះពុទ្ធសាសនាមួយដែរ។ ម្យ៉ាងទៀតព្រះពុទ្ធសាសនាជាប្រភពនៃការ

បណ្តុះបណ្តាលអក្សរសាស្ត្រនិងតម្រិះវិជ្ជាផ្សេងៗ។

មនុស្សដែលបានបួសក្នុងព្រះពុទ្ធសាសនាមានតម្លៃខ្ពស់ជាងមនុស្សដែលពុំបានបួស ព្រោះអ្នកស្រុកតែងយល់ថា អ្នកបួសជាមនុស្សស្គាល់បាបបុណ្យ គុណទោសច្បាស់លាស់ ហើយប្រជាជនខ្មែរមានជំនឿម្យ៉ាងទៀតថា "***បួសនេនសងគុណម្តាយ បួសភិក្ខុសងគុណឪពុក***" ដែលជំនឿទាំងនេះបានជ្រាបចូលជ្រៅនៅក្នុងសន្តានចិត្តប្រជាជនខ្មែរទូទាំងប្រទេស រហូតដល់ពេលរៀបចំទុកដាក់កូនចៅឱ្យមានប្តី-ប្រពន្ធ ក៏គេនិយមប្រកាន់រើសរកតែបុរសណាដែលបានបួសរៀន។ អ្នកស្រុកស្រែចម្ការនៅប្រកាន់ទំនៀមទម្លាប់ខាងលើនេះជាប់រហូតដល់សព្វថ្ងៃ ប៉ុន្តែមិនសូវតឹងរ៉ឹងដូចកាលពីដើមទេ ព្រោះនាពេលបចុចប្បន្ននេះមានសាលារៀនរដ្ឋច្រើនសម្រាប់ការបណ្តុះនិស្ស័យនិងបណ្តុះនូវតម្រិះវិជ្ជាផ្សេងៗ។ ប្រជាជនខ្មែរភាគច្រើនយល់ថា "អ្នកបួសជាមនុស្សប្រសើរ" ទើបគេហៅ **បព្វជ្ជាបេក្ខ:** និង **ឧបសម្បទាបេក្ខ:** ថា "នាគ"។ "**បំបួសនាគ**" គឺ **បំបួសមនុស្សប្រសើរ** ៕

**ឯកសារពិគ្រោះ**

. សៀវភៅរៀនភាសាខ្មែរថ្នាក់ទី ៦ មេរៀនទី៦៖ ***ទំនៀមទម្លាប់ ប្រពៃណីខ្មែរ (ពិធីបំបួសនាគ)***។

. ពេជ សល់ ***ពិធីប្រចាំដប់ពីរខែ ក្រុមប្រជុំទំនៀមទម្លាប់ខ្មែរ*** ឆ្នាំ១៩៦៦។

. ស៊ូ កិត្យា; ហ៊ាន សុខុម; ហ៊ុន ធីរិទ្ធ ***ពិធីបំបួសនាគនៅប្រទេសកម្ពុជា អតីតកាល និងបច្ចុប្បន្នកាល*** មជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវជាន់ខ្ពស់។

. អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា, ស៊ុន ចាន់ដឹប ***ដំណើរជីវិតមនុស្សខ្មែរ មើលតាមពិធីឆ្លងវ័យ(២០០៧)*** បោះពុម្ពនៅភ្នំពេញដោយរោងពុម្ព ហនុមានទេសចរណ៍។